# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៤៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពនៃដំណើរការរបស់អង្គភាពផ្តល់សេវាសាធារណៈក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ឱ្យកាន់តែប្រសើរឡើងតាមរយៈការកំណត់ឱ្យមានការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី៖

- គោលការណ៍និងនីតិវិធីនៃការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈ
- ការលើកទឹកចិត្តចំពោះអង្គភាពផ្តល់សេវាសាធារណៈគំរូប្រចាំឆ្នាំ។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានសាធារណៈ ដែលជាអង្គភាពផ្តល់សេវាសាធារណៈ សរសេរអក្សរកាត់ អ.ផ.ស. ក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល រួមមាន៖

- **វិស័យអប់រំ** : វិទ្យាល័យ អនុវិទ្យាល័យ សាលាបឋមសិក្សា និងសាលាមត្តេយ្យសិក្សា
- **វិស័យសុខាភិបាល** : មន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ និងមណ្ឌលសុខភាព។

## ជំពូកទី២

## គោលការណ៍និងនីតិវិធីនៃការអនុវត្ត និងការវាយតម្លៃ អង្គភាពផ្តល់សេវាសាធារណៈ

**មាត្រា៤ .-**

ការដាក់ឱ្យដំណើរការនៃការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងកម្រិតឬប្រភេទណាមួយខាងលើអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវសម្រេចដោយប្រកាសអន្តរក្រសួងរវាងក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នសាមី។

**មាត្រា៥ .-**

ការវាយតម្លៃនិងការទទួលស្គាល់ អ.ផ.ស. គំរូ ត្រូវអនុវត្តដោយឈរលើគោលការណ៍សុក្រឹតភាព តម្លាភាព និងសមិទ្ធកម្មរបស់ អ.ផ.ស. ដែលស្ថិតនៅក្នុងវិស័យ កម្រិត ប្រភេទ និងពេលវេលានៃឆ្នាំត្រូវវាយតម្លៃតែមួយដូចគ្នាដោយធ្វើការពិនិត្យនិងវាយតម្លៃផ្អែកលើលក្ខណៈវិនិច្ឆ័យគោល ដូចខាងក្រោម៖

- ស្តង់ដាសេវាសាធារណៈដែលមានចែងនៅក្នុងឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈដែលជាឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ៤៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ

- ស្តង់ដាឬនិយាមនៃការផ្តល់សេវាតាមវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ឬ ក្រសួងសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ
- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងអង្គភាព រួមមានការរៀបចំផែនការថវិកា ការគ្រប់គ្រងចំណូល ការអនុវត្តចំណាយ ទ្រព្យសម្បត្តិរដ្ឋ និងលទ្ធកម្មសាធារណៈ
- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅក្នុងអង្គភាព
- ការរៀបចំនិងកែលម្អបរិស្ថានអង្គភាព
- ទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ សហគមន៍ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងការចូលរួមវាយតម្លៃពីអ្នកប្រើប្រាស់សេវាសាធារណៈ
- ការដោះស្រាយបញ្ហាប្រឈមនានាជាមួយមន្ត្រី ប្រជាពលរដ្ឋ ឬសហគមន៍
- ការផ្តួចផ្តើមគំនិតថ្មីៗនិងនវានុវត្តន៍ ដើម្បីធ្វើឱ្យអង្គភាពមានដំណើរការកាន់តែប្រសើរ។

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ ដែលមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ ត្រូវចាត់ចែងរៀបចំឱ្យមានតារាងវាយតម្លៃនិងដាក់ពិន្ទុផ្អែកលើគោលការណ៍ដែលមានកំណត់ក្នុងវាក្យខណ្ឌទី១ នៃមាត្រានេះ ដើម្បីប្រើប្រាស់ជាមូលដ្ឋាននៃការពិនិត្យនិងវាយតម្លៃ អ.ផ.ស. ក្នុងដំណាក់កាលនីមួយៗអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

ចំពោះ អ.ផ.ស. ដែលស្ថិតនៅតាមក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ការពិនិត្យនិងវាយតម្លៃដើម្បីជ្រើសរើស អ.ផ.ស. គំរូ ក្រោមវិសាលភាពនៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាម ៣(បី)ដំណាក់កាល ដូចខាងក្រោម៖

- ដំណាក់កាលទី១ : ការវាយតម្លៃនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ សរសេរអក្សរកាត់ គ.វ.ក.
- ដំណាក់កាលទី២ : ការវាយតម្លៃនៅថ្នាក់រាជធានី ខេត្ត ត្រូវអនុវត្តដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត សរសេរអក្សរកាត់ គ.វ.រ.
- ដំណាក់កាលទី៣ : ការវាយតម្លៃថ្នាក់ជាតិ ត្រូវអនុវត្តដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ សរសេរអក្សរកាត់ គ.វ.ជ.។

ចំពោះ អ.ផ.ស. ដែលស្ថិតនៅតាមរាជធានី ខេត្ត ការពិនិត្យនិងវាយតម្លៃដើម្បីជ្រើសរើស អ.ផ.ស. គំរូ ក្រោមវិសាលភាពនៃអនុក្រឹត្យនេះ ត្រូវអនុវត្តតាម ២(ពីរ)ដំណាក់កាល ដូចខាងក្រោម៖

- ដំណាក់កាលទី១ : ការវាយតម្លៃនៅថ្នាក់រាជធានី ខេត្ត ត្រូវអនុវត្តដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត សរសេរអក្សរកាត់ គ.វ.រ.
- ដំណាក់កាលទី២ : ការវាយតម្លៃថ្នាក់ជាតិ ត្រូវអនុវត្តដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ សរសេរអក្សរកាត់ គ.វ.ជ.។

**មាត្រា៧ .-**

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ មានសមាសភាព ដូចខាងក្រោម៖

- អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាងនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ..... ប្រធាន

- តំណាងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សមាជិក
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ឬ ប្រធានការិយាល័យសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ សមាជិក
- មន្ត្រីជំនាញ១រូប នៃការិយាល័យអប់រំ យុវជន និងកីឡា ឬ ការិយាល័យសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ លេខាធិការ

សមាសភាពជាក់ស្តែងរបស់ គ.វ.ក. ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ច ដូចខាងក្រោម៖

- ណែនាំ ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងវិស័យអប់រំ និង វិស័យសុខាភិបាល ដល់គ្រប់ អ.ផ.ស. ដែលស្ថិតក្នុងក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ ក្រោមដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការនៃការវាយតម្លៃនិងជ្រើសរើសអង្គភាពផ្តល់សេវាសាធារណៈគំរូនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌ ចាប់ពីសប្តាហ៍ទី១ នៃខែកក្កដា ក្នុងឆ្នាំនីមួយៗ
- ទទួលពាក្យស្នើសុំចុះឈ្មោះរបស់អង្គភាពផ្តល់សេវាសាធារណៈសម្រាប់ការប្រកួតប្រជែង
- ធ្វើការពិនិត្យ វាយតម្លៃ និងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូត្រឹមចំនួន២(ពីរ) ប៉ុណ្ណោះក្នុងក្រុង ស្រុក ខណ្ឌ ដើម្បីបញ្ជូនបន្តមកប្រកួតប្រជែងនៅថ្នាក់រាជធានី ខេត្ត ដោយមានភ្ជាប់ជាមួយនូវឯកសារគាំទ្រផ្សេងៗ យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែសីហា ក្នុងឆ្នាំនីមួយៗ។

**មាត្រា៨** -

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត មានសមាសភាព ដូចខាងក្រោម៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាងនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាន
- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត សមាជិក
- នាយករដ្ឋបាលសាលារាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរមុខងារសាធារណៈឬតំណាង សមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឬតំណាង សមាជិក
- ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ឬ ប្រធានមន្ទីរសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ សមាជិក
- ប្រធានមន្ទីរបរិស្ថានឬតំណាង សមាជិក
- មន្ត្រីជំនាញ ១(មួយ)រូប នៃមន្ទីរអប់រំ យុវជន និងកីឡា ឬ មន្ទីរសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ លេខាធិការ

សមាសភាពជាក់ស្តែងរបស់ គ.វ.រ. ត្រូវកំណត់ដោយដីការបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត មានភារកិច្ច ដូចខាងក្រោម៖

- ណែនាំ ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និង វិស័យសុខាភិបាល ដល់គ្រប់ អ.ផ.ស. និង គ.វ.ក. ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត
- ណែនាំដល់ គ.វ.ក. ឱ្យបំពេញភារកិច្ចស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន
- ការវាយតម្លៃរបស់ គ.វ.រ. ត្រូវបានបែងចែកទៅតាមកម្រិតនៃ អ.ផ.ស. ដូចខាងក្រោម៖

  ១. ការវាយតម្លៃ អ.ផ.ស. ដែលស្នើដោយ គ.វ.ក.

  - ធ្វើការពិនិត្យ វាយតម្លៃ និងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូត្រឹមចំនួន ២(ពីរ)ប៉ុណ្ណោះពីក្នុងចំណោមបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈ ដែលស្នើឡើងដោយ គ.វ.ក.។ ក្នុងករណីចាំបាច់ គ.វ.រ. អាចអញ្ជើញតំណាងអង្គភាពផ្តល់សេវាសាធារណៈពាក់ព័ន្ធដើម្បីចូលរួមផ្តល់ព័ត៌មានដោយផ្ទាល់ ឬ ចាត់ចែងឱ្យមានការចុះពិនិត្យស្ថានភាពរបស់អង្គភាពនីមួយៗដោយផ្ទាល់
  - អនុវត្តការពិនិត្យនិងវាយតម្លៃ ព្រមទាំងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូឱ្យបានចប់សព្វគ្រប់ យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែកញ្ញា ក្នុងឆ្នាំនីមួយៗ
  - រៀបចំបញ្ជូនបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់រាជធានី ខេត្ត ដោយមានភ្ជាប់ជាមួយនូវឯកសារគាំទ្រផ្សេងៗ យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែតុលា ក្នុងឆ្នាំនីមួយៗ ដើម្បីចូលរួមប្រកួតប្រជែងនៅថ្នាក់ជាតិ។

  ២. ការវាយតម្លៃ អ.ផ.ស. ដែលស្ថិតក្នុងថ្នាក់រាជធានី ខេត្ត

  - ផ្សព្វផ្សាយអំពីការចាប់ផ្តើមដំណើរការនៃការវាយតម្លៃនិងជ្រើសរើសអង្គភាពផ្តល់សេវាសាធារណៈគំរូនៅក្នុងដែនសមត្ថកិច្ចរបស់រាជធានី ខេត្ត ចាប់ពីសប្តាហ៍ទី១ នៃខែកក្កដា ក្នុងឆ្នាំនីមួយៗ
  - ទទួលពាក្យស្នើសុំចុះឈ្មោះសម្រាប់ការប្រកួតប្រជែងរបស់អង្គភាពផ្តល់សេវាសាធារណៈដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់រាជធានី ខេត្តផ្ទាល់
  - ធ្វើការពិនិត្យ វាយតម្លៃ និងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូយ៉ាងច្រើនត្រឹមចំនួន ២(ពីរ)ប៉ុណ្ណោះក្នុងរាជធានី ខេត្ត ដើម្បីបញ្ជូនបន្តមកប្រកួតប្រជែងនៅថ្នាក់ជាតិ។ ក្នុងករណីចាំបាច់ គ.វ.រ. អាចអញ្ជើញតំណាងអង្គភាពផ្តល់សេវាសាធារណៈពាក់ព័ន្ធដើម្បីចូលរួមផ្តល់ព័ត៌មានដោយផ្ទាល់ ឬ ចាត់ចែងឱ្យមានការចុះពិនិត្យស្ថានភាពរបស់អង្គភាពនីមួយៗដោយផ្ទាល់មុនពេលសម្រេចបញ្ជូនបេក្ខភាពមកថ្នាក់ជាតិ
  - អនុវត្តការពិនិត្យនិងវាយតម្លៃ ព្រមទាំងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូឱ្យបានចប់សព្វគ្រប់ យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែសីហា ក្នុងឆ្នាំនីមួយៗ
  - រៀបចំបញ្ជូនបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈគំរូថ្នាក់រាជធានី ខេត្ត ដោយមានភ្ជាប់ជាមួយនូវឯកសារគាំទ្រផ្សេងៗ យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែកញ្ញា ក្នុងឆ្នាំនីមួយៗ ដើម្បីចូលរួមប្រកួតប្រជែងនៅថ្នាក់ជាតិ។

**មាត្រា៩.-**

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | ប្រធាន |
| - តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| - តំណាងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | អនុប្រធានប្រចាំការ |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងអប់រំ យុវជន និងកីឡា ឬ ក្រសួងសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ | សមាជិក |
| - តំណាងក្រសួងបរិស្ថាន | សមាជិក |
| - តំណាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| - តំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | សមាជិក |
| - មន្ត្រីជាន់ខ្ពស់នៃអគ្គនាយកដ្ឋានជំនាញរបស់ក្រសួងអប់រំ យុវជន និងកីឡា ឬ ក្រសួងសុខាភិបាល ផ្អែកលើករណីពាក់ព័ន្ធ | សមាជិក |
| - តំណាងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | លេខាធិការ |

សមាសភាពជាក់ស្តែងរបស់ គ.វ.ជ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបំពេញមុខងារជាសេនាធិការរបស់ គ.វ.ជ.។

គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិមានភារកិច្ច ដូចខាងក្រោម៖

- ណែនាំ ផ្សព្វផ្សាយ និងផ្តល់ព័ត៌មានទាំងឡាយពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និង វិស័យសុខាភិបាល
- ផ្សព្វផ្សាយការដាក់ឱ្យអនុវត្តការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងឆ្នាំនីមួយៗ
- ណែនាំ ផ្តល់ការគាំទ្រ និងជំនួយបច្ចេកទេសដល់ គ.វ.ក. និង គ.វ.រ. ឱ្យបំពេញភារកិច្ចស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន
- រៀបចំឱ្យមានតារាងវាយតម្លៃនិងដាក់ពិន្ទុ ដើម្បីប្រើប្រាស់ជាមូលដ្ឋាននៃការពិនិត្យនិងវាយតម្លៃ អ.ផ.ស. ក្នុងដំណាក់កាលនីមួយៗ របស់ គ.វ.ក. និង គ.វ.រ.

- ធ្វើការពិនិត្យ វាយតម្លៃ និងជ្រើសសម្រាំងបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈ ដែលស្នើឡើងដោយ គ.វ.រ. ព្រមទាំងសម្រេចកំណត់ចំណាត់ថ្នាក់របស់ជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈគំរូចំនួន ១០(ដប់)ប្រចាំឆ្នាំ។ ការពិនិត្យនិងវាយតម្លៃរបស់ គ.វ.ជ. ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា១០ នៃអនុក្រឹត្យនេះ
- ពិនិត្យនិងដោះស្រាយបណ្តឹងតវ៉ាផ្សេងៗ ពាក់ព័ន្ធនឹងដំណើរការនៃការពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈ
- រៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយអំពីអង្គភាពផ្តល់សេវាសាធារណៈគំរូ ព្រមទាំងបទពិសោធន៍ និងឧត្តមានុវត្តន៍ទាំងឡាយដែលគាំទ្រដល់ការកែលម្អដំណើរការរបស់អង្គភាពសាធារណៈ
- រៀបចំពិធីប្រកាសនិងផ្តល់រង្វាន់ប្រចាំឆ្នាំដល់អង្គភាពជ័យលាភី សិក្ខាសាលា សន្និសីទ និងព្រឹត្តិការណ៍ផ្សេងៗ ដើម្បីលើកកម្ពស់និងបំផុសការយល់ដឹង និងស្មារតីនៃការប្រកួតប្រជែងក្នុងការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរ។

**មាត្រា១០ ..**

ការពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈដោយ គ.វ.ជ. ត្រូវអនុវត្តផ្អែកលើនីតិវិធី ដូចខាងក្រោម៖

១. **ការជ្រើសសម្រាំងអង្គភាពផ្តល់សេវាសាធារណៈដំណាក់កាលបឋម** : គ.វ.ជ. ត្រូវពិនិត្យនិងវាយតម្លៃ អ.ផ.ស. ដែលស្នើដោយ គ.វ.រ. ផ្អែកលើសំណុំឯកសារដែល គ.វ.ជ. ទទួលបាន ដើម្បីជ្រើសសម្រាំងយកបេក្ខភាពអង្គភាពផ្តល់សេវាសាធារណៈល្អជាងគេត្រឹមចំនួន ១៥(ដប់ប្រាំ)។ ការវាយតម្លៃដើម្បីជ្រើសសម្រាំងអង្គភាពផ្តល់សេវាសាធារណៈដំណាក់កាលបឋម ត្រូវអនុវត្តយ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែវិច្ឆិកា ក្នុងឆ្នាំនីមួយៗ។

២. **ការវាយតម្លៃជ្រើសសម្រាំងបេក្ខភាពជ័យលាភីអង្គភាពផ្តល់សេវាសាធារណៈ** : គ.វ.ជ. ត្រូវអញ្ជើញតំណាងអង្គភាពផ្តល់សេវាសាធារណៈដែលបានជាប់ក្នុងការជ្រើសសម្រាំងទាំងចំនួន ១៥(ដប់ប្រាំ) មកធ្វើបទបង្ហាញនិងផ្តល់ព័ត៌មានផ្ទាល់ដល់ គ.វ.ជ.។ គ.វ.ជ. ត្រូវធ្វើការពិនិត្យនិងវាយតម្លៃ អ.ផ.ស ដោយផ្អែកលើសំណុំឯកសារ បទបង្ហាញ ការផ្តល់ព័ត៌មាន ទិន្នន័យ និងការសាកសួរផ្ទៀងផ្ទាត់ ដើម្បីជ្រើសសម្រាំងយក អ.ផ.ស. គំរូល្អជាងគេ ចំនួន ១០(ដប់) និងសម្រេចកំណត់ចំណាត់ថ្នាក់ អ.ផ.ស. ពីលំដាប់ខ្ពស់ថ្នាក់លេខ ៦ ចុះទៅលំដាប់ថ្នាក់លេខ ១០ យ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែធ្នូ ក្នុងឆ្នាំនីមួយៗ។

៣. **ការពិនិត្យនិងវាយតម្លៃសម្រេចចុងក្រោយ** : គ.វ.ជ. ត្រូវចាត់ចែងឱ្យក្រុមការងារចម្រុះរបស់ គ.វ.ជ. ចុះពិនិត្យ អ.ផ.ស. ដែលមានលំដាប់ថ្នាក់ខ្ពស់ជាងគេទាំង ៥(ប្រាំ) ផ្ទាល់នៅហ្នឹងកន្លែង ដើម្បីពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ និងព័ត៌មានផ្សេងៗ ព្រមទាំងការសាកសួរយកព័ត៌មានបន្ថែមពីភាគីដែលពាក់ព័ន្ធ។ ក្រុមការងារចម្រុះត្រូវធ្វើរបាយការណ៍ជូន គ.វ.ជ. ដើម្បីធ្វើការពិនិត្យ វាយតម្លៃ និងសម្រេចចុងក្រោយចំណាត់ថ្នាក់ អ.ផ.ស. ពីលំដាប់ខ្ពស់ថ្នាក់លេខ ១ ចុះទៅលំដាប់ថ្នាក់លេខ ៥។

គ.វ.ជ. ត្រូវអនុវត្តការពិនិត្យនិងវាយតម្លៃ អ.ផ.ស អនុលោមតាមនីតិវិធីខាងលើឱ្យបានចប់សព្វគ្រប់យ៉ាងយូរត្រឹមសប្តាហ៍ទី៤ នៃខែមករា ក្នុងឆ្នាំបន្ទាប់។

គ.វ.ជ. ត្រូវធ្វើរបាយការណ៍និងលើកសំណើជូននាយករដ្ឋមន្ត្រី ដើម្បីសម្រេចទទួលស្គាល់ អ.ផ.ស. គំរូទាំង១០(ដប់) ដោយអនុក្រឹត្យ។

## ជំពូកទី៣
## ការលើកទឹកចិត្តចំពោះអង្គភាពផ្តល់សេវាសាធារណៈគំរូ

**មាត្រា១១.-**

រាជរដ្ឋាភិបាលនឹងផ្តល់ពានរង្វាន់ និង/ឬ វិញ្ញាបនបត្របញ្ជាក់ទទួលស្គាល់ដល់ អ.ផ.ស. គំរូទាំង១០(ដប់) តាមវិស័យ កម្រិត និងប្រភេទ ដូចមានចែងក្នុងមាត្រា៥ ព្រមទាំងថវិកាជារង្វាន់លើកទឹកចិត្ត តាមលំដាប់ថ្នាក់ដូចខាងក្រោម៖

១. អ.ផ.ស. គំរូ លំដាប់ថ្នាក់ទី១ : ២០០ ០០០ ០០០(ពីររយលាន)រៀល
២. អ.ផ.ស. គំរូ លំដាប់ថ្នាក់ទី២ : ១៥០ ០០០ ០០០(មួយរយហាសិបលាន)រៀល
៣. អ.ផ.ស. គំរូ លំដាប់ថ្នាក់ទី៣ : ១០០ ០០០ ០០០(មួយរយលាន)រៀល
៤. អ.ផ.ស. គំរូ លំដាប់ថ្នាក់ទី៤ : ៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល
៥. អ.ផ.ស. គំរូ លំដាប់ថ្នាក់ទី៥ : ៦០ ០០០ ០០០(ហុកសិបលាន)រៀល
៦. អ.ផ.ស. គំរូ ចាប់ពីលំដាប់ថ្នាក់ទី៦ ដល់ ទី១០: ៤០ ០០០ ០០០(សែសិបលាន)រៀល

**មាត្រា១២.-**

ថវិកាជារង្វាន់លើកទឹកចិត្តដែល អ.ផ.ស. ទទួលបានត្រូវចាត់ចែងប្រើប្រាស់ដូចខាងក្រោម៖

- ៦០ (ហុកសិប)% នៃថវិកាប្រើប្រាស់សម្រាប់ការលើកទឹកចិត្តដល់មន្ត្រីបម្រើការងារក្នុងអង្គភាព
- ៤០ (សែសិប)% សម្រាប់ការអភិវឌ្ឍអង្គភាព។

ការចាត់ចែងនិងប្រើប្រាស់ថវិកាខាងលើ ត្រូវសម្រេចដោយគណៈគ្រប់គ្រង អ.ផ.ស. បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយមន្ត្រីនៅក្នុងអង្គភាព។

**មាត្រា១៣.-**

ថវិកាសម្រាប់គាំទ្រដល់ដំណើរការនៃការវាយតម្លៃនិងការទទួលស្គាល់ ព្រមទាំងប្រាក់រង្វាន់សម្រាប់ផ្តល់ជូនដល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ត្រូវស្ថិតក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងមុខងារសាធារណៈ។

ចំណាយសម្រាប់ប្រតិបត្តិការវាយតម្លៃរបស់គណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ក្រុង ស្រុក ខណ្ឌ និងគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត ត្រូវជាបន្ទុករបស់អង្គភាពសាមីនីមួយៗ។

## ជំពូកទី៤
## សហាទិធាន

**មាត្រា១៤.-**

ក្នុងករណីចាំបាច់ គ.វ.ជ. អាចចេញសេចក្តីណែនាំបន្ថែម ដើម្បីធានាឱ្យការដាក់ដំណើរការនៃការវាយតម្លៃនិងការទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព អនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អាចលើកសំណើកែប្រែបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ តាមការចាំបាច់។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ រោច ខែ ពិសាខ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ